## វិភាគទានប្រវត្តិវិទ្យា ៖

# កាត់ទោសសាធារណរដ្ឋ, ត្រូវកាត់ទោសសីហនុ ហើយនិងសហរដ្ឋអាមេរិក !!!

Sihanouk, fauteur de guerre

ដោយ សុទ្ធ-ប៉ូលិន ⋆ ថ្ងៃទី២២ វិច្ឆិកា ២០០៥

⋆⋆⋆ បើគេតម្រូវឲ្យកាត់ទោសពួកខ្មែរក្រហម (អំពីបទប្រល័យពូជសាសន៍) គេត្រូវកាត់ទោសសម្តេចសីហនុ ដែលជាស្តេចក្រហម ជាមួយនឹងប្រទេសយួនហើយនិងប្រទេសចិន ។ ពីព្រោះបើគ្មានស្តេចសីហនុ ប្រទេសយួនហើយនិងប្រទេសចិនទេ ក៏គ្មានសង្គ្រាមប្រល័យពូជសាសន៍ខ្មែរបានកើតឡើងផងដែរ នៅកម្ពុជានៃឆ្នាំ ១៩៧០ ។ រឿងនេះ មតិពិភពលោកបានជ្រួតជ្រាបអស់រលីងទៅហើយ ! ។

⋆⋆⋆ ក៏ប៉ុន្តែ បើគេតម្រូវឲ្យកាត់ទោស «សាធារណរដ្ឋខ្មែរ» របស់ឧត្តមសេនិយលន់-នល់វិញ... គេក៏ត្រូវតែកាត់ទោសសម្តេចសីហនុផងដែរ ដែលបានស៊ីគ្រលុំជាមួយនឹងសហរដ្ឋអាមេរិក ដើម្បីយកភ្លើងសង្គ្រាមមកដុតប្រទេសកម្ពុជា តាំងពីឆ្នាំ១៩៦៩មកម៉្លេះ... រួចហើយស្តេចលីលាអាវ៉ាសែ ក៏យកឧក្រិដ្ឋកម្មប៉ុន្មានភ្នំនេះ ទៅលាបប្រឡាក់លើឧត្តមសេនិយលន់-នល់ ។ ប៉ុន្តែរឿងនេះ មតិពិភពលោកមិនបានជ្រួតជ្រាបទេ...។ តាមពិត «សាធារណរដ្ឋខ្មែរ» ជាកូនសំអប់ដែលព្រះបិតាសីហនុបង្កបង្កើតឡើងសំរាប់ឲ្យយួនសម្លាប់តែប៉ុណ្ណោះឯង !! ។

❑

❑ ❑

<u>ព្រឹត្តិការណ៍បន្តបន្ទាប់គ្នា (កាលវិទ្យា Chronologie) ដែលបង្កើតឲ្យមានភ្លើងសង្គ្រាមឆាបឆេះនៅប្រទេសកម្ពុជា ដែលកំពុងកាឡាខ្លួនក្លាយពីព្រះរាជាណាចក្រទៅជាសាធារណរដ្ឋ</u> ៖

<u>មករា ១៩៦៤</u> ៖ កិច្ចព្រមព្រៀងសម្ងាត់រវាងស្តេចសីហនុ ហើយនិងសហរដ្ឋអាមេរិក ដែលអនុញ្ញាតឲ្យកងទ័ពអាមេរិកាំងរុករានទន្ទ្រានទឹកដីខ្មែរ ។ សូមអានអត្ថបទមួយរបស់លោក Milton Osborne ៖

«...បើទោះជាមានលក្ខណៈត្រឹមតែជានិមិត្តរូបក្តី, កិច្ចការដំណើរ (របស់អ្នកស្រី Jacqueline Kennedy) បានក្លាយទៅជាមូលដ្ឋាន សំរាប់បង្កើតឲ្យមានទស្សនកិច្ចដ៏សំខាន់មួយទៀតរបស់ទូតអាមេរិកាំងប្រចាំប្រទេសឥណ្ឌា, លោក Chester Bowles, ពីរខែក្រោយមក ពោលគឺនៅក្នុងខែមករា ១៩៦៨ ។ នៅក្នុងឱកាសទស្សនកិច្ចលើកនេះ រដ្ឋមន្ត្រីទី១របស់សីហនុឈ្មោះ សឺន-សាន បានបញ្ជាក់យ៉ាងច្បាស់លាស់ថា ប្រទេសកម្ពុជាមានចំណង់ប្រាថ្នាចងស្ពានមេត្រីឡើងវិញ ជាមួយនឹងសហរដ្ឋអាមេរិក, ទំនាក់ទំនងមួយដែលនៅទីបំផុត បានប្រព្រឹត្តឡើងនៅមុនដំណាច់ឆ្នាំដដែលនោះ ។ ប៉ុន្តែរឿងសំខាន់បំផុត គឺនៅក្នុងឱកាសទស្សនកិច្ចរបស់លោក Bowles, សីហនុបានផ្លាស់ប្តូរជំហររបស់ទ្រង់ទាំងស្រុង ដែលបណ្តាលឲ្យកើតមានផលវិបាកភ្លាមៗនិងវែងឆ្ងាយចំពោះអនាគតនៃប្រទេសកម្ពុជា ។ ដោយទទួលស្គាល់មិនចំពោះ (Tacitly) ថាពួកកងកម្លាំងកុម្មុយនិស្តវៀតណាមបានយកទឹកដីខ្មែរប្រើប្រាស់ជាឈ្នាន់សំរាប់ធ្វើសង្គ្រាមពិតមែន - ប្រការមួយដែលទ្រង់តែងតែបដិសេធជាផ្លូវការ - សីហនុក៏បានប្រាប់លោក Bowles ថា ទ្រង់នឹងមិនប្រឆាំងនឹងកងទ័ពអាមេរិកាំង ដែលឆ្លងកាត់ចូលក្នុងទឹកដីកម្ពុជាទេ ក្នុងលក្ខណៈណាដែលពួកគេដេញតាមខ្មាំងសត្រូវយ៉ាងប្រផាប់ប្រភីង («in hot pursuit of their enemy») ។ ការអនុលោមរបស់សីហនុនេះ ក៏បានក្លាយទៅជាមូលដ្ឋាន នៃការភ្ជាប់ចំណងទូតឡើងវិញរវាងប្រទេសទាំងពីរ ។
(កកន ៖ ដើម្បីដាក់ចំណងទូតឡើងវិញជាមួយសហរដ្ឋអាមេរិក, ស្តេចសីហនុបានអនុញ្ញាតឲ្យអាមេរិកាំង ធ្វើអន្តរាគមន៍យោធានៅលើទឹកដីប្រទេសកម្ពុជា ។ នៅក្នុងកិច្ចព្រមព្រៀងនេះ លោកឧត្តមសេនិយលន់-នល់ ឥតមានស្នាមម្រាមដៃបន្តិចសោះ ដែលថ្ងៃក្រោយមកស្តេចសីហនុបានចោទថា បានលក់ខ្លួនឲ្យចក្រពត្តិអាមេរិកដើម្បីដុល្លារ) ។

«នៅក្នុងប្រការសង្គ្រាមដែនគោក (សំណេរបន្តរបស់លោក Milton Osborne) នៅវៀតណាម ដែលកំពុងតែឆាបឆេះសន្ធោរសន្ធៅ កងទ័ពអាមេរិកាំងលើកនេះ ក៏មានលទ្ធភាពដ៏ប្រសើរជាងកាលពីមុន ដើម្បីធ្វើការសំពាធទៅលើខ្មាំងសត្រូវរបស់ពួកគេ ពោលគឺអាចជំរុញពួកកងទ័ពកុម្មុយនិស្ត ចូលកាន់តែជ្រៅទៅក្នុងជំរករបស់ខ្លួននៅប្រទេសកម្ពុជា ។ ជាជោគវាសនាអភ័ព្វជាងគេទាំងអស់សំរាប់ប្រទេសកម្ពុជា ហើយដោយមិនគិតអំពីសេចក្តីបដិសេធជារឿយៗ ពីសំណាក់ Henry Kissinger, ទីក្រុងវ៉ាស៊ិនតោន ក៏បានកាច់មួលគោលជំហររបស់ស្តេចសីហនុ ដែលគ្រាន់តែអនុញ្ញាតឲ្យអាមេរិកាំងដេញតាមចាប់ខ្មាំងយ៉ាងប្រផាប់ប្រភីង» យកទៅប្រើជាមូលដ្ឋានសំរាប់ធ្វើយុទ្ធនាការទម្លាក់គ្រាប់បែក យ៉ាងសន្ធឹកសន្ធាប់ទៅលើប្រទេសកម្ពុជា ពីចន្លោះឆ្នាំ១៩៦៩និងឆ្នាំ១៩៧៣ ដែលបណ្តាលឲ្យមានការបំផ្លិចបំផ្លាញ និងការបង់ខាតនៃជីវិតដ៏សំបើមធំធេង» ។ (ដកស្រង់ចេញពីសៀវភៅ Prince of light, Prince of Darkness - p.195-196) ។

ថ្ងៃទី១៨ មិនា ១៩៦៩ ៖ ដោយសារតែសេចក្តីអនុញ្ញាតរបស់ស្តេចសីហនុ ហាង់ តី-គីស្សីងគ្ញើ ក៏បានចាប់ផ្តើមធ្វើការទម្លាក់គ្រាប់បែកជាសម្ងាត់ (Secret Bombings) ទៅលើទឹកដីខ្មែរ ពីថ្ងៃខែខាងលើនេះឯង ពោលគឺមួយឆ្នាំមុនថ្ងៃទី១៨ មិនា ១៩៧០ ដែលស្តេចសីហនុរត់បោលទៅធ្វើជាស្តេចយៀកកុង ។ សូមអានអត្ថបទរបស់លោក Jessi Hanhimäki ៖

«កិច្ចប្រតិបត្តិការអាហារពេព្រឹក (Operation Breakfast) បានចាប់ផ្តើមឡើងនៅថ្ងៃទី១៨ មិនា (១៩៦៩) ។ យោងតាមលោក Haldeman (មន្ត្រីជាន់ខ្ពស់មួយរូបនៅសេតវិមាន) នៅថ្ងៃស្អែកឡើង គីស្សីងគ្ញើរ មានទឹកមុខ«សប្បាយរីករាយ»ជាពន់ពេក ដោយពត៌មានដំបូង ដែលបានទទួលបង្ហាញថា យុទ្ធនាការ(ទម្លាក់គ្រាប់បែក) បានទទួលជោគជ័យ ។ នៅក្នុងរយៈពេល១៤ខែ បន្ទាប់ពីការចាប់ផ្តើមនៃកាតទម្លាក់គ្រាប់បែកនៃខែមិនា១៩៦៩ សហរដ្ឋអាមេរិកបានធ្វើយុទ្ធនាការទម្លាក់គ្រាប់បែកដោយយន្តហោះ បេ-៥២ ចំនួន៣,៦៥០ដង ទៅលើទឹកដីប្រទេសកម្ពុជា ។ (កកន ៖ ក្នុងរយៈពេល១៤ខែ ពីខែមិនា១៩៦៩ ទៅដល់ខែមេសា១៩៧០, សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់បែក បេ-៥២ ចំនួន១០ដងក្នុង១ថ្ងៃ ទៅលើប្រទេសកម្ពុជាអព្យាក្រឹត្យ) ។ (ដកស្រង់ចេញពីសៀវភៅ «Henry Kissinger, The Flawed architect» p.44-45, by Jessi M. Hanhimäki - New York 2004) ។

១១ មិថុនា ១៩៦៩ ៖ ស្តេចសីហនុ (ក្នុងសម័យ«រដ្ឋាភិបាលនៃសំណាងចុងក្រោយ» របស់ប៉ែន-នុត) ក៏បានដាក់ឲ្យមានចំណងទូតជាមួយសហរដ្ឋអាមេរិកឡើងវិញ ។ តើដើម្បីអរគុណអាមេរិកាំង ដែលបានធ្វើយុទ្ធនាការទម្លាក់គ្រាប់បែកឥតមានឈប់ឈរលើប្រទេសកម្ពុជា ចំនួន២ខែមកហើយនោះឬ ??

១២ សីហា ១៩៦៩ ៖ ស្តេចសីហនុតែងតាំងឧត្តមសេនិយលន់-នល់ ជានាយករដ្ឋមន្ត្រីនៃ«រដ្ឋាភិបាលស្រោចស្រង់ជាតិ» ដើម្បីស្រោចស្រង់សេដ្ឋកិច្ចជាតិដុនដាប ដោយសុំជំនួយអាមេរិកាំង និងដើម្បីដេញយៀកកុង ឲ្យចេញពីទឹកដីខ្មែរ ។ តាមពិតស្តេចសីហនុកំពុងលាបពណ៌ឧត្តមសេនិយលន់-នល់ ឲ្យទៅជាមន្ត្រីក្បត់ជាតិលក់ខ្លួនឲ្យអាមេរិកាំង (គឺជាការយកបាយស្ងាទៅលាបមាត់ពពែ)...

៦ មករា ១៩៧០ ៖ ស្តេចសីហនុរត់ចោលស្រុក ពោលគឺលែងទទួលការខុសត្រូវ បន្ទាប់ពីបានកាន់កាប់អំណាចផ្តាច់ការ ក្នុងឋានៈជាព្រះប្រធាននៃ«សង្គមរាស្ត្រនិយម» និងស៊ីគ្រលុំជាមួយជនពុករលួយគ្រប់ប្រភេទ អស់ចំនួន១៥ឆ្នាំ ។ ក្នុងប្រការនេះស្តេចសីហនុបានទម្លាក់អំរែក(ឬថ្មបាក់) ឲ្យជនខ្សត់ខ្សោយម្នាក់ឈ្មោះ ឧត្តមសេនិយលន់-នល់ ដើម្បីប្រឈមមុខនឹងសភាពការណ៍ (លោកឧត្តមសេនិយមានទាហានតែ៣៥,០០០នាក់ ប្រដាប់ដោយអាវុធគំរាំងចែត្រ ដើម្បីទប់ទល់នឹងយៀកកុង នៅក្នុងទឹកដីខ្មែរចំនួន ២០០,០០០នាក់ ប្រដាប់ដោយគ្រឿងអាវុធទំនើប និងមានបទពិសោធន៍សង្គ្រាមយ៉ាងជ្រៅ) ។ ស្តេចសីហនុដឹងច្បាស់ណាស់ថា លោកលន់-

នល់គ្មានផ្លូវសង្ឃឹមយកឈ្នះទៅលើពួកយៀកកុងបានទេ ។

**ថ្ងៃ ១១ មិនា ១៩៧០** ៖ ស្តេចសីហនុបានបញ្ជាឲ្យប្រជាពលរដ្ឋខ្មែរទាំងអស់ ងើបឡើងដេញឃ្មួនឈ្លានពាន ។ នៅកណ្តាលដំណើរនៃមហាបាតុកម្មមួយ ដែលព្រះបិតាជាតិអង្គឯងជាអ្នកបំផុសបំផុល... ស្រាប់តែស្តេចសីហនុបានប្រែក្រឡាប់សារជាថ្មី ដោយចោទប្រកាន់«រដ្ឋាភិបាលស្រោចស្រង់ជាតិ», រដ្ឋសភា និងពួកបាតុករទាំងអស់ថា ជាពួក«លក់ខ្លួនឲ្យចក្រពត្តិអាមេរិកាំងដើម្បីប្រាក់ដុល្លារ» ។ តាមពិតស្តេចសីហនកំពុងតែ«លេងល្បែងកំប្លុកកំប្លែង» សំដែងល្បិចកលឲ្យរដ្ឋាភិបាលទម្លាក់ទ្រង់ ដើម្បីជាលេសឲ្យព្រះអង្គរត់ទៅធ្វើស្តេចយៀកកុងដោយសុវត្ថិភាពតែប៉ុណ្ណោះ

**១៨ មិនា ១៩៧០** ៖ ថ្ងៃដែលសមាជិករដ្ឋសភាខ្មែរទាំងមូលបានបោះឆ្នោតទម្លាក់ស្តេចសីហនុ ពីមុខតំណែង «ប្រមុខរដ្ឋមួយជីវិត» គឺជាថ្ងៃដែលសម្តេចសីហនុ ហើយនិងសម្តេចប៉ែន-នុត កំពុងជិះយន្តហោះសូវៀត ពីមូស្គូទៅប៉េកាំង ដើម្បីទៅបង្កើត «រដ្ឋាភិបាលខ្មែរក្រហមប្រល័យពូជសាសន៍» ក្នុងគោលបំណាងមកពិឃាត <u>រដ្ឋាភិបាលសាធារណរដ្ឋលន់-នល់ ដែលសីហនុខ្លួនឯងទើបបានតែងតាំង អស់រយៈពេល១៩ខែប៉ុណ្ណោះ</u> ។ (សូមអាន My war with the CIA by Norodom Sihanouk) ។

ដូច្នេះ មេចោរក្បត់ជាតិពីររូបដ៏ធំជាងគេនៅក្នុងប្រវត្តិសាស្ត្រនៃកម្ពុជាទំនើប គឺសម្តេចសីហនុ ហើយនិងសម្តេចប៉ែន-នុត បន្ទាប់ពីបានយកភ្លើងសង្គ្រាម «ប្រល័យពូជសាសន៍» មកដុតប្រទេសកម្ពុជារួចកាលណាហើយ ក៏នាំគ្នារត់បោលទៅទីក្រុងប៉េកាំងនៅថ្ងៃទី១៨ មិនា ១៩៧០ ដើម្បីទៅស្រែកបង្អើលចិនព្រិននៅប៉េកាំង ព្រមទាំងពិភពលោកផងដែរថា មហាឃាតករ មហាភេរវករ ក្បត់ជាតិលក់ស្រុកខ្មែរឲ្យចក្រពត្តិអាមេរិកាំង គឺឧត្តមសេនិយលន់-នល់ឯណោះទៅវិញទេ ។